## ៣_ ទីស្តីការរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០០១

## ប្រកាសលេខ ០៨៤ ប្រក.កសក.ប្រ
## ស្តីពីការបង្កើតការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទ

-----

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញប្រកាសលេខ ១៤៧០ ប្រក.កសក ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ១៩៩០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់នាយកដ្ឋានជលផល
- តាមសំណើរបស់ប្រធាននាយកដ្ឋានជលផល

## សំរេច

**ប្រការ ១ :**

បង្កើតការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទ ស្ថិតក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានជលផល នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ប្រការ ២ :

ការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទ មានភារកិច្ចដូចតទៅ :

- ជាសេនាធិការឱ្យនាយកដ្ឋាន ជលផល លើការងារស្រាវជ្រាវផ្នែកសេដ្ឋកិច្ចសង្គម និងអភិវឌ្ឍន៍សហគមន៍នេសាទ ។
- រៀបចំប្រព័ន្ធការងារស្រាវជ្រាវ ផ្នែកសេដ្ឋកិច្ចសង្គម និងវិភាគសេដ្ឋកិច្ចជលផល ។
- រៀបចំការអភិរក្ស ធនធានជលផលជាមួយសហគមន៍នេសាទ ។
- ចងក្រងលក្ខន្តិកៈដើម្បីគ្រប់គ្រង និងអភិវឌ្ឍន៍សហគមន៍នេសាទ ។
- សហការជំរុញការងារអភិវឌ្ឍន៍សហគមន៍នេសាទ ។
- ទំនាក់ទំនងជាមួយបណ្តាសមាគម អង្គការជាតិ អង្គការអន្តរជាតិនានា និងស្ថាប័នពាក់ព័ន្ធដើម្បីជំរុញ និងលើកកំពស់កិច្ចអភិវឌ្ឍន៍សហគមន៍នេសាទ ។

**ប្រការ ៣ :**

ការរៀបចំរចនាសម្ព័ន្ធ និងការប្រព្រឹត្តិទៅរបស់ការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទ អាស្រ័យដោយប្រធាននាយកដ្ឋានជលផល កំណត់សំរេច ។

**ប្រការ ៤ :**

ការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទ ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានជាជំនួយការ ។

**ប្រការ ៥ :**

អគ្គនាយកក្រសួង អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស ប្រធាននាយកដ្ឋាន ផែនការស្ថិតិ និងសហប្រតិបត្តិការអន្តរជាតិ ប្រធាននាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ និងប្រធាននាយកដ្ឋានជលផល ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃដែលបានចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រីស្តីទី

ហត្ថលេខា និង ត្រា

**ចំនួ តុងអ៊ីច**

***